Khmer | ភាសាខ្មែរ

SES
NSW STATE EMERGENCY SERVICE

# ដឹងពី ហានិភ័យព្យុះភ្លៀង របស់អ្នក

## ព្យុះភ្លៀងបង្កើតនូវគ្រោះថ្នាក់ផ្សេងៗ



ព្យុះភ្លៀងអាចកើតឡើងគ្រប់ទីកន្លែង និងគ្រប់ពេលវេលា។

មានសញ្ញាធម្មជាតិនៃព្យុះភ្លៀងជាច្រើន ដូចជា៖

- ភ្លៀងផ្គរ និងរន្ទះ
- ខ្យល់ធ្វើឱ្យអន្តរាយ
- មានភ្លៀងខ្លាំង ភ្លៀងជោគជាំ
- ទឹកជំនន់ភ្លាមៗ
- រលកខ្លាំងធំៗ ការឡើងកញ្ជ្រោលនៃមហាសមុទ្រ និងការរិចរិលនៅតាមឆ្នេរសមុទ្រ
- ព្រិល

## ព្យុះភ្លៀង អាចបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរ



ព្យុះភ្លៀងអាចធ្វើឱ្យខូចខាតដល់ផ្ទះ រថយន្ត និងទ្រព្យសម្បត្តិផ្សេងទៀត



ព្យុះភ្លៀងអាចបណ្តាលឱ្យដើមឈើ មែកឈើ និងខ្សែភ្លើងដួលរលំ



ព្យុះភ្លៀងអាចបណ្តាលឱ្យមានការខូចខាត និងទឹកជំនន់នៅតំបន់ឆ្នេរសមុទ្រ



ព្យុះភ្លៀងអាចបណ្តាលឱ្យដាច់អគ្គិសនី ហ្គាស ការទំនាក់ទំនង និងលទ្ធភាពទទួលបានទឹកស្អាត



ព្យុះភ្លៀងអាចបណ្តាលឱ្យមានទឹកជំនន់ភ្លាមៗទៅលើផ្លូវ និងទ្រព្យសម្បត្តិ តំបន់ទំនាប ផ្លូវកាត់ទីមានទឹកឬភក់ និងព្រែកឬអូរតូចៗ

ក្នុងស្ថានភាពគំរាមកំហែងដល់ជីវិត **ហៅទូរសព្ទទៅលេខសូន្យបីង (000)**

សម្រាប់ជំនួយសង្គ្រោះបន្ទាន់សម្រាប់ទឹកជំនន់ ព្យុះភ្លៀង និងរលកយក្សស៊ូណាមិ សូមហៅទូរសព្ទទៅ **NSW SES** តាមលេខ **132 500**។

**www.ses.nsw.gov.au/languages**

@NSWSES NSWSES NSWSES

Khmer | ភាសាខ្មែរ

NSW STATE EMERGENCY SERVICE

# ដឹងពី ហានិភ័យព្យុះភ្លៀង របស់អ្នក



## ត្រៀមខ្លួនសម្រាប់ ព្យុះភ្លៀង

- ទាញយកកម្មវិធី **គ្រោះថ្នាក់នៅជិតខ្ញុំ (the Hazards Near Me app)** ចូលទៅក្នុងឧបករណ៍ចល័តរបស់អ្នក ហើយបង្កើត **តំបន់ឃ្លាំមើល** សម្រាប់តំបន់នានាដែលអ្នករស់នៅ ធ្វើការ និងទៅលេង។
- រក្សាទបង្ហូរទឹក ទីធ្លា យ៉រផ្ទះ និងដំបូលរបស់អ្នកឱ្យស្អាត និងមានសណ្តាប់ធ្នាប់ល្អ។
- ត្រូវប្រាកដថាអ្នកមានការធានារ៉ាប់រងត្រឹមត្រូវ។

## រៀបចំ កញ្ចប់សង្គ្រោះបន្ទាន់

កញ្ចប់សង្គ្រោះបន្ទាន់របស់អ្នកត្រូវតែមាន៖

- វិទ្យុចល័តដែលមានថ្មបម្រុងទុក
- ពិលដែលមានថ្មបម្រុង
- ទៀន និងឈើគូសមិនជ្រាបទឹក
- កញ្ចប់សង្គ្រោះបឋម (ជាមួយនឹងការផ្គត់ផ្គង់ចាំបាច់សម្រាប់គ្រួសាររបស់អ្នក)
- ឯកសារសំខាន់ៗ រួមមានលេខទូរសព្ទទំនាក់ទំនងក្នុងគ្រាអាសន្ន
- ច្បាប់ចម្លងនៃផែនការក្នុងគ្រាមានអាសន្នទាំងអស់
- ថង់មិនជ្រាបទឹកសម្រាប់ដាក់វត្ថុមានតម្លៃ។

| | |
|---|---|
| ក្នុងស្ថានភាពគំរាមកំហែងដល់ជីវិត **ហៅទូរសព្ទទៅលេខសូន្យបីង (000)** | សម្រាប់ជំនួយសង្គ្រោះបន្ទាន់សម្រាប់ទឹកជំនន់ ព្យុះភ្លៀង និងរលកយក្សស៊ូណាមិ សូមហៅទូរសព្ទទៅ **NSW SES** តាមលេខ **132 500**។ |

**www.ses.nsw.gov.au/languages**

@NSWSES NSWSES NSWSES